# ពិព័រណ៍ពាណិជ្ជកម្មក្រុងកែប

The Kep Trade Fair 2008

ពិព័រណ៍ពាណិជ្ជកម្ម ក្រុងកែប ២០០៨

## សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមជូនដំណឹងជាសាធារណៈថា : ក្រសួងពាណិជ្ជកម្ម នឹងរៀបចំធ្វើ **“ពិព័រណ៍ពាណិជ្ជកម្មក្រុងកែប ឆ្នាំ ២០០៨”** ។ ពិព័រណ៍ ពាណិជ្ជកម្ម នេះ នឹងត្រូវប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៧-២៩ ខែ ធ្នូ ឆ្នាំ ២០០៨ នាបរិវេណសាលាក្រុងកែប ដោយមាន ព្រឹត្តិការណ៍ផ្សេងៗទៀតអមក្នុងកំឡុងពេលនៃការរៀបចំ ធ្វើពិព័រណ៍គឺ ទិវាបុណ្យអុំទូកក្រុងកែប ឆ្នាំ ២០០៨ និងការប្រគំតន្ត្រីដោយនិស្សិតសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នាពេលរាត្រី ។ ការរៀបចំព្រឹត្តិការណ៍ទាំងអស់នេះ ក្នុងបំណងជំរុញវិស័យពាណិជ្ជកម្មអោយមានភាពរស់ រវើកទូទាំង ខេត្ត-ក្រុង នៃប្រទេសកម្ពុជា និង ដើម្បីបង្កើតនូវល័ក្ខខ័ណ្ឌពិសេសសំរាប់សហគ្រាស ក្នុង និង ក្រៅប្រទេស អាចធ្វើការផ្លាស់ប្តូរគំនិតយោបល់គ្នាទៅវិញទៅមកបង្ហាញពីសេវាកម្ម ឬ ផលិតផលថ្មីៗ និងរបកគំហើញនូវទស្សនាទាន ពាណិជ្ជកម្មទូទាំងខេត្ត-ក្រុង ។

តាមសេចក្តីជូនដំណឹងនេះ ក្រសួងពាណិជ្ជកម្មក៏សូមគោរព យាង និង អញ្ជើញ ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ចូលរួមការតាំងពិព័រណ៍ និងទស្សនាដោយ មេត្រីភាព ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមបណ្តាក្រុមហ៊ុន សហគ្រាស អង្គការ សមាគមទាំងឡាយដែលមានបំណងចូលរួមការតាំងពិព័រណ៍ពាណិជ្ជកម្ម **ក្រុងកែប ឆ្នាំ ២០០៨** សូមអញ្ជើញមកដាក់ពាក្យនៅនាយកដ្ឋានជំរុញពាណិជ្ជកម្ម ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

រាល់ព័តិមានលំអិត សូមទាក់ទងតាមទូរស័ព្ទលេខ : ០១២ ៨១៤ ៤១៨, ០១៦ ៥២២ ៣៥០ ឬ មកទាក់ទងផ្ទាល់នៅនាយកដ្ឋានជំរុញពាណិជ្ជកម្ម អគារលេខ : ៦៥-៦៩, ផ្លូវលេខ ១៣៦ សង្កាត់ផ្សារកណ្តាលទី ១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

***សូមអរគុណ !***